# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ មករា ឆ្នាំ២០១៤

## និងទិសដៅការងារ ខែ កុម្ភៈ ឆ្នាំ២០១៤

(ពីថ្ងៃទី០១/០១/២០១៤ ដល់ ថ្ងៃទី៣១/០១/២០១៤)

ខែមករាឆ្នាំ២០១៤នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យនៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៣-២០១៥) និងទិសដៅការងារដែលបានដាក់ចេញកាលពី ខែធ្នូ ឆ្នាំ២០១៣ កន្លងទៅ ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៏ច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន, កងរាជអាវុធហត្ថ, ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមានក្នុងរាជធានីភ្នំពេញ , ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ឆ្នាំង, កំពង់ចាម, សៀមរាប, ស្វាយរៀង, ស្ទឹងត្រែង, បាត់ដំបង, កោះកុង, បន្ទាយមានជ័យ, ពោធិ៍សាត់ និង ខេត្តក្រចេះ ។ ក្នុងនោះយើងបានកត់សំគាល់ឃើញមានបទល្មើសចរាចរគ្រឿងញៀនប្រភេទ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ចំនួនបីករណីធំៗ ដែលពីរករណី ត្រូវបានមន្ទីរប្រឆាំងគ្រឿងញៀនបង្ក្រាបនៅរាជធានីភ្នំពេញ និង មួយករណីទៀតបង្ក្រាបនៅខេត្តស្ទឹងត្រែង ។

ទន្ទឹមនោះ ក៏មានសកម្មភាពចរាចរនាំចេញនូវសារធាតុគីមីផ្សំ (ផ្សឺដូ-អេហ្វេទ្រីន) តាមរូបភាពលាក់បង្កប់ក្នុងកញ្ចប់បញ្ញើប្រៃសណីយ៍បម្រុងនាំចេញទៅក្រៅប្រទេស និងការនាំចូលនូវសារធាតុគីមីផ្សំ (តេស្តបឋមមានសញ្ញាវិជ្ជមានសារធាតុតូលុយអែន) ពីតំបន់ព្រំដែនកម្ពុជា-វៀតណាម តាមច្រកនៃខេត្តតាកែវផងដែរ ។

## II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. *អំពីការងារដឹកនាំ*

លើការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានបន្តណែនាំ និងដឹកនាំបញ្ជាលើការងារជាគោលសំខាន់ៗ រួមមាន :

**ក- អំពីគោលការណ៍ណែនាំ និងការដឹកនាំបញ្ជា** ឯកឧត្តមបានណែនាំឱ្យអគ្គលេខាធិការដ្ឋាន :

- ចុះទៅដកយកសំណាកម្សៅល្លិរម្សៀត មកធ្វើកោសលវិច័យដើម្បីបញ្ជាក់ការសង្ស័យថានៅក្នុងម្សៅនេះ មានផ្ទុកសារធាតុដែលអាចផ្សំជាគ្រឿងញៀនបាន ។
- ចុះទៅពិនិត្យសារធាតុរាវដែលសមត្ថកិច្ចគយ-រដ្ឋាករ សាខាខេត្តតាកែវ បានដកហូតនិងរក្សាទុក ។
- ចុះទៅពិនិត្យកញ្ចប់បញ្ញើប្រៃសណីយ៍ ដែលមានលាក់បង្កប់សារធាតុគីមីផ្សំ បម្រុងនាំចេញទៅក្រៅប្រទេស ។
- បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល បំប៉ន ស្តីពីការព្យាបាល ការថែទាំ និងការផ្តល់ប្រឹក្សាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។
- ខិតខំជំរុញប្រែក្លាយ "មណ្ឌលបណ្តុះបណ្តាលជនពិការស៊ីវិល" នៅខេត្តបន្ទាយមានជ័យ ទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទូទៅ សម្រាប់អ្នកប្រើប្រាស់គ្រឿងញៀនដែលបានព្យាបាលធូរស្រាល ។
- ពិនិត្យសកម្មភាពរបស់អង្គការ "ពន្លឺកុមារកម្ពុជា" ដើម្បីផ្តល់ការគាំទ្រដល់អង្គការនេះបន្ត ។
- ចូលរួមកិច្ចប្រជុំស្តីពីការចាប់ផ្តើមរៀបចំផែនការជាតិអភិវឌ្ឍន៍កុមាររយៈពេល១០ឆ្នាំ (២០១៥ -២០២៥) ។

**ខ- អំពីលិខិតបទដ្ឋានគតិយុត្ត** ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានណែនាំអគ្គលេខាធិការដ្ឋានឱ្យ :

- បន្តសម្របសម្រួលនិងជំរុញការរៀបចំសេចក្តីព្រាង " គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តន៍ច្បាប់ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ " និង " គោលនយោបាយ និង គោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីម្ស៉ុល/ស៊ីរ៉ាំង នៅកម្ពុជា " ឱ្យបានឆាប់រហ័ស ។
- ពិនិត្យលើខ្លឹមសារសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**គ- អំពីកិច្ចសវនាការជាមួយភ្ញៀវអន្តរជាតិ** ឯកឧត្តម បានទទួលជួបពិភាក្សាការងារពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនជាមួយឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសឹង្ហបុរី កាលពីថ្ងៃទី០៩/០១/២០១៤ ។

### ២. *អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពី **ខែធ្នូ ឆ្នាំ២០១៣** កន្លងទៅ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

#### ២.១. *ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក៏ដូចជាក្រសួង-ស្ថាប័នជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈ

កម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធី ប្រចាំថ្ងៃ-សប្តាហ៍-ខែ, ការអប់រំតាមសហគមន៍ និងការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមសហគមន៍ ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

**ដោយឡែក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បាន :

- ចូលរួមផ្តល់បទសម្ភាសន៍ក្នុងកម្មវិធី សភាអ៊ីនធឺណេត នៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពីយុទ្ធសាស្ត្រជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី២៩/០១/២០១៤ ។
- ផ្តល់ការគាំទ្របន្តទៀតដល់អង្គការ ពន្លឺកុមារកម្ពុជា ចំពោះការអនុវត្តសកម្មភាពគម្រោង "ត្រួតពិនិត្យការប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍មូលដ្ឋាន" ដំណាក់កាលទី៤ (២០១៤-២០១៦) ដែលនឹងពង្រីកទៅដល់ ស្រុកកងមាស (ខេត្តកំពង់ចាម) និងស្រុកគងពិសី (ខេត្តកំពង់ស្ពឺ) ។
- ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន នៅសាកលវិទ្យាល័យ វេស្ទើន មានសាស្ត្រាចារ្យ និងនិស្សិត ចូលរួម **៣០០** នាក់ ។
- សហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ជាតិ, វិទ្យុ-ទូរទស្សន៍បាយ័ន, វិទ្យុ-ទូរទស្សន៍ម៉ាយធីវី, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តគោលដៅ, ក្រុមហ៊ុនហង្សមាស, ក្រុមហ៊ុនខារ៉ាបាវ, ក្រុមហ៊ុនទូរស័ព្ទចល័ត Smart mobile បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈកម្មវិធីប្រគំតន្ត្រីស្រុកស្រែ, តន្ត្រីទេសចរណ៍ខារ៉ាបាវ, តន្ត្រីទេសចរណ៍ Smart mobile នៅរាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, ពោធិ៍សាត់, កែប, ក្រចេះ, កំពង់ចាម, កំពង់ធំ, សៀមរាប, តាកែវ, កំពង់ស្ពឺ និង ខេត្តកោះកុង ដែលមានមហាជនចូលរួមទស្សនាសរុប **២៧៦.៨០០** នាក់ ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ និងបណ្តុះបណ្តាលជនបង្គោលនៅតាមសហគមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និង គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន *៨* គឺ ខេត្តព្រះសីហនុ, ព្រះវិហារ, ស្វាយរៀង, កំពង់ឆ្នាំង, បាត់ដំបង, កណ្តាល, ក្រចេះ និង ខេត្តកំពង់ស្ពឺ នៅក្នុងខែមករាឆ្នាំ២០១៤នេះ មានមហាជនចូលរួម ***៣៦៧.៣១៤ នាក់*** លើ **១៩២.៦៩៧** នាក់ នៃខែធ្នូ ឆ្នាំ២០១៣ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

### ***២.២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ខែមករានេះ មន្ត្រីអនុវត្តន៍ច្បាប់នៅតែបន្តយកចិត្តទុកដាក់ចូលរួមសហការគ្នាបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ***ក. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន***

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន សរុបរួម **៧៥** ករណី លើ ៥៤ ករណី នៃខែធ្នូ ឆ្នាំ២០១៣
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន សរុបរួម **១៦៧** នាក់ លើ ១១៧ នាក់ នៃខែធ្នូ ឆ្នាំ២០១៣

ក្នុងចំនួនបទល្មើសគ្រឿងញៀនទាំង ៧៥ ករណី និង ជនសង្ស័យទាំង ១៦៧ នាក់ ខាងលើនេះ គឺ :

✓ **បទល្មើសគ្រឿងញៀន** ដែលបង្ក្រាបដោយ **កងកម្លាំងនគរបាលជាតិ** មាន ៥២ ករណី, ជនសង្ស័យ ១២៩ នាក់

✓ **បទល្មើសគ្រឿងញៀន** ដែលបង្ក្រាបដោយ **កងរាជអាវុធហត្ថ** មាន ២៣ ករណី, ជនសង្ស័យ ៣៨ នាក់

- **ជនសង្ស័យ** ដែលបានឃាត់ខ្លួនទាំង **១៦៧** នាក់ ខាងលើ មានប្រុស ១៤១ នាក់ ស្រី ២៦ នាក់ ក្នុងនោះ មាន ០៥ សញ្ជាតិ គឺ **ខ្មែរ** ១៦១ នាក់ ( ស្រី ២៥ នាក់), **វៀតណាម** ៣ នាក់ ( ស្រី ១ នាក់), **នីហ្សេរីយ៉ា** ០១ នាក់ ( ប្រុស), **ឥស្លាម** ០១ នាក់ ( ប្រុស), **អូស្ត្រាលី** ០១ នាក់ ( ប្រុស) ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន មេតំហ្វេតាមីនគ្រាប់ (WY) ២០៦,១៥ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៣.៧០៥,៧៩ ក្រាម, កញ្ឆា ១០.០០០ ក្រាម, ដើមកញ្ឆា ៩៥១, តួលុយអែន ១.៤៣២ គ.ក្រ ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក រួមមាន** : ម៉ូតូ ២៤ គ្រឿង, រថយន្ត ៦ គ្រឿង, ប្រាក់កម្ពុជា ៤.៨៧៩.៥០០ រៀល, ប្រាក់អាមេរិក ៨៥៦ ដុល្លារ, ប្រាក់ថៃ ១២០ បាត **ដូចមានក្នុងតារាងឧប-សម្ព័ន្ធ ទី២** ។

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៥ ដីកា = មនុស្ស ៥ នាក់ ( ប្រុស) ជនជាតិខ្មែរ ។

***ខ. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងសុខាភិបាល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង **ខែមករា ឆ្នាំ២០១៤** នេះ មានដូចខាងក្រោម :

- សារធាតុគីមី គិតជា គីឡូក្រាម ចំនួន ១.៦០៩.៤៧៥ គ.ក្រ និង ២៥ អំពូល និង ១០០ ប្រអប់
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទចំនួន ៣ គ.ក្រ និង ១.២៧៩ ក្រាម **ដូចមានក្នុងតារាងឧប-សម្ព័ន្ធទី២**

***គ. ការងារកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន***

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែមករា ឆ្នាំ២០១៤ នេះ សរុបបានចំនួន ១០២ ករណី = ១២២ សំណាក ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀនទាំង** ១០ សំណាក និង **សំណាកវិជ្ជមាន** ១១២ សំណាក ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៩៦ សំណាក = ៨២ %     -មេតំហ្វេតាមីនគ្រាប់ (WY) ១៥ សំណាក = ១០ %

-ហេរ៉ូអ៊ីន ១ សំណាក = ១ %

ក្រៅពីការធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដោយអនុវត្តតាមគោលការណ៍ណែនាំ និងដឹកនាំបញ្ជារបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បាន :

- ចុះទៅពិនិត្យសារធាតុរាវ ដែលសមត្ថកិច្ចគយ-រដ្ឋាករ សាខាខេត្តតាកែវ ឃាត់ទុកកាលពីថ្ងៃទី ០១/០១/២០១៤ ។
- ចុះទៅដកយកសំណាកម្សៅរឺល្បិរមៀត នៅខេត្តពោធិ៍សាត់ យកមកធ្វើការវិភាគ ។

**ដោយឡែក** គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ នៃក្រសួងការពារជាតិ បានរៀបចំកិច្ចប្រជុំពេញអង្គស្តីពី លទ្ធផលការងាររបស់គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ឆ្នាំ២០១០-២០១៣ ។

### ***២.៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម***

#### ***ក. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់***

ការងារនេះ អគ្គលេខាធិការដ្ឋាន បាន :

- រៀបចំកិច្ចប្រជុំជាមួយស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ កាលពីថ្ងៃទី០៩/០១/២០១៤ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងឯកសារ ទី១). ស្តីពី គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តន៍ច្បាប់ ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ និងទី២). ឯកសារស្តីពី គោលនយោបាយ និងគោលការណ៍ណែនាំ ស្តីពីការអនុវត្តកម្មវិធី ម្ទុល-ស៊ីរ៉ាំង នៅកម្ពុជា ។
- ចូលរួមប្រជុំពិនិត្យ លើឯកសារស្តីពី បរិស្ថានច្បាប់ទាក់ទងនឹងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍របស់ប្រទេសកម្ពុជា កាលពីថ្ងៃទី១០/០១/២០១៤ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីក្តាប់បាននិងបញ្ជ្រាបបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។
- បានចូលរួមប្រជុំពិភាក្សារៀបចំឯកសារទស្សនាទាន ដើម្បីអន្តរាគមន៍ចំពោះអ្នកចាក់គ្រឿងញៀន (Concept note on B.CoPCT among PWID) ។
- បាននិងកំពុងរៀបចំផែនការប្រតិបត្តិលើវិស័យគ្រឿងញៀនពាក់ព័ន្ធនឹងជំងឺអេដស៍ ដើម្បីប្រគល់ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំគ្រប់ជ្រុងជ្រោយ និងពហុវិស័យ សម្រាប់ឆ្នាំ២០១៤ ។
- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីមេរោគអេដស៍ ជំងឺអេដស៍ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី២២/០១/២០១៤ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី "ការបង្កើតយន្តការឆ្ពោះទៅរកគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹងនៅកម្ពុជា" តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា កាលពីថ្ងៃទី ២៧/០១/២០១៤ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។

#### ***ខ. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម***

**ការងារនេះ** អគ្គលេខាធិការដ្ឋាន ដោយមានកិច្ចសហការល្អជាមួយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) បានរៀបចំសិក្ខាសាលាបូកសរុប និងពិនិត្យលើលទ្ធផលការងារស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី១៤-១៥/០១/២០១៤ ដែលមានមន្ត្រីពាក់ព័ន្ធចូលរួម ចំនួន <u>៤០</u> នាក់ ។

### ***២.៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់***

**អគ្គលេខាធិការដ្ឋាន** បាន :

- រៀបចំពិធីទទួលសម្ភារៈមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ពីគម្រោង HAARP តាមរយៈអង្គការ FHI360 កាលពី

ថ្ងៃទី១៥/០១/២០១៤ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សម្រាប់កម្មវិធីពង្រឹងសមត្ថភាពមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

- សហការជាមួយអង្គការ UNODC ក្រោមថវិកាគម្រោង PATROL រៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងទៅនឹងការរត់ពន្ធឆ្លងកាត់ព្រំដែន សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន កម្ពុជា-វៀតណាម កាលពីថ្ងៃទី០២-០៦/០១/២០១៤ នៅទីក្រុងបាវិត ខេត្តស្វាយរៀង ដែលមានសិក្ខាកាមកម្ពុជាចូលរួម ចំនួន ១៧ រូប ។
- សហការជាមួយការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) តាមរយៈគម្រោង PATROL ចុះទៅអង្កេតការអនុវត្តកម្មវិធី "ភូមិ-ឃុំ ស[១]" ឬហៅថ្មីថា "ភូមិ-ឃុំបៃតងគ្មានគ្រឿងញៀន" តាមផែនការជាតិរបស់ អ.ជ.ប.គ.ញ នៅស្រុកកំរៀង ខេត្តបាត់ដំបង និង ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ពីថ្ងៃទី២១-២៤/០១/២០១៤ ។ គោលបំណងរបស់គម្រោងគឺជួយពង្រឹងភូមិទាំងនោះ ដោយផ្តោតជាសំខាន់ទៅលើវិស័យកសិកម្ម សុខភាព និង ការផ្លាស់ប្តូរព័ត៌មានសន្តិសុខតាមព្រំដែន ។ តាមរយៈគម្រោងខាងលើ អង្គការ UNODC នឹងបន្តជួយពង្រីកភូមិបៃតងគ្មានគ្រឿងញៀន នៅភូមិ ៣ ក្នុងឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង និងភូមិ ៧ ទៀត នៅក្នុងក្រុងប៉ោយប៉ែត និង ឃុំអូរបីជាន់ របស់ខេត្តបន្ទាយមានជ័យ ។
- សហការជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា រៀបចំកែសម្រួលខ្លឹមសារឯកសារបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ស្តីពី យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន សម្រាប់កម្មវិធីបណ្តុះបណ្តាលដល់និស្សិតគ្រប់រូបនៃបណ្ឌិត្យសភានគរបាលកម្ពុជា ឆ្នាំ២០១៤ ។

**ដោយឡែក** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកណ្តាល បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤ ដែលមានមន្ទីរ-អង្គភាពជំនាញ អង្គការសង្គមស៊ីវិល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ក្រុង-ស្រុក ចូលរួមចំនួន **៣៣១** នាក់ ។

### ***២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានខិតខំបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ តាមរយៈយន្តការ ទ្វេភាគី ត្រីភាគី និងពហុភាគី ជាមួយបណ្តាប្រទេសជិតខាង ប្រទេសក្នុងអនុតំបន់ តំបន់ និង អន្តរជាតិ មានដូចខាងក្រោម :

**ការងារក្នុងប្រទេស** បានចូលរួមកិច្ចប្រជុំអន្តរក្រសួង នៃអនុគណៈកម្មការសន្តិសុខ និងការបរទេស សម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម នាថ្ងៃទី១៤/០១/២០១៤ នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមប្រជុំក្រុមសម្របសម្រួលអន្តរជាតិ (Operation Cobra 2) ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន កាលពីថ្ងៃទី ០៦-២៦ ខែមករា ឆ្នាំ២០១៤ នៅទីក្រុង បាងកក ។ សម្រាប់ប្រទេសកម្ពុជា អង្គការ UNODC តាមរយៈគម្រោង PATROL

---

[1] ភូមិ-ឃុំ ស ជាភូមិ-ឃុំ ដែលភាគីកម្ពុជា-ថៃ បានបង្កើតនៅក្នុងខេត្តគោលដៅមួយចំនួន តាមបណ្តោយព្រំដែន (កម្ពុជា-ថៃ) ។

ដែលកំពុងអនុវត្តក្នុងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ បានគាំទ្រដល់អគ្គលេខាធិការដ្ឋាន នូវកម្មវិធីបណ្តុះបណ្តាលចល័ត ស្តីពីការបណ្តុះបណ្តាលអំពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដល់មន្ត្រីអនុវត្តច្បាប់ន៍កម្ពុជា ដែលកំពុងបម្រើការងារនៅតំបន់ដាច់ស្រយាលតាមបណ្តោយព្រំដែន ។

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចំនួន ២ រូប ទៅចូលរួមក្នុងកិច្ចប្រជុំមន្ត្រីទំនាក់ទំនង ស្តីពីគម្រោងថ្មីគាំទ្រភាពជាដៃគូនៃបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ កាលពីថ្ងៃទី២០-២១/០១/២០១៤ នៅទីក្រុងគុនមិញ សាធារណរដ្ឋប្រជាមានិតចិន ។

***ការងារផ្សេងៗ :***

ដើម្បីបំពេញឱ្យការងារត្រួតពិនិត្យគ្រឿងញៀនពហុវិស័យនិងអនុវត្តតាមគោលការណ៍ណែនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១០/០១/ ២០១៤ ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែកុម្ភៈ ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ត្រៀមផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពី អត្តសញ្ញាណ និងឥទ្ធិពលនៃគ្រឿងញៀន ( ថ្ងៃទី២៦/០២/២០១៤) ។

១.២. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្ត និងនៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ ។

១.៣. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និង ឯកជន ។

១.៤. បន្តជំរុញការងារបណ្តុះបណ្តាលព្រះសង្ឃបង្គោល ក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន រោងចក្រ-សហគ្រាស និងនៅតាមសហគមន៍ ។

### ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយមន្ទីរប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងគ្រឿងញៀន រាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការស្រាវជ្រាវរកខ្សែរយៈទាក់ទងដែលនៅសេសសល់ពាក់ព័ន្ធនឹងករណីធំ

ដែលបង្ក្រាបបានកន្លងមក ។

២.២. បន្តកិច្ចសហប្រតិបត្តិការផ្តល់ព័ត៌មានគ្រឿងញៀនឱ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាង ។

២.៣. ជំរុញកិច្ចប្រជុំឱ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ កម្ពុជា-ឡាវ កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

២.៤. បន្តសហការសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

២.៥. បន្តសហការជាមួយអង្គការ UNODC ដើម្បីដំណើរការវិភាគឱ្យបានច្បាស់លាស់ពីរុក្ខជាតិវល្លិរមៀត ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. រៀបចំគម្រោងសម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធផ្នែកព្យាបាល និង ផ្នែកស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគម្រោងតម្រូវការសម្ភារៈ ឱសថ ដែលត្រូវផ្តល់ដោយភាគីវៀតណាម ។

៣.២. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និង ស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៣. កែសម្រួលសេចក្តីព្រាង "គោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធី ម្ញុល/ស៊ីរ៉ាំង នៅកម្ពុជា និង គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តច្បាប់ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៣.៤. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៥. បន្តពង្រឹងសមត្ថភាពការងារព្យាបាលដោយផ្អែកលើសហគមន៍ តាមប្រព័ន្ធសុខាភិបាលដែលមានស្រាប់ (មន្ទីរពេទ្យបង្អែក-មណ្ឌលសុខភាព) នៅទូទាំងប្រទេស ដោយយកបទពិសោធន៍តាមខេត្តបន្ទាយមានជ័យ និងខិតខំសហការសម្របសម្រួលលើការងារព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមប៉ុស្តិ៍សុខភាពពន្ធនាគារ ។

៣.៦. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣.៧. ពិនិត្យលើសំណើសុំអនុវត្តកម្មវិធី ម្ជុល/ស៊ីរ៉ាំង របស់អង្គការ កសាង ។

៣.៨. រៀបចំក្រុមប្រតិភូ ដើម្បីចូលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅថ្ងៃទី២០/០២/២០១៤ ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. សហការសម្របសម្រួល និងជំរុញដំណើរការការងាររបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៤.២. រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នានា នៅតាមខ្សែបន្ទាត់ព្រំដែន ។

៤.៣. រៀបចំទីកន្លែងសម្រាប់ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយម៉ាស៊ីនកុំព្យូទ័រ (CBT) ។

៤.៤. បន្តការចូលរួមធ្វើបទឧទ្ទេសនាមអំពីសភាពការណ៍គ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនគរបាលរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ។

៤.៥. ចុះត្រួតពិនិត្យ និងជំរុញការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន នៅតាមបណ្តាខេត្តដែលមានការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

៤.៦. រៀបចំកែសម្រួលឯកសារបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

៤.៧. បន្តសហការជាមួយអង្គការ UNODC ចុះជួយពង្រឹងការអនុវត្ត ភូមិបៃតងគ្មានគ្រឿងញៀន នៅខេត្តបន្ទាយមានជ័យ និង ខេត្តបាត់ដំបង ។

៤.៨. បន្តកិច្ចសហការជាមួយអង្គការ UNODC តាមរយៈគម្រោង PATROL ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលចល័តស្តីពី "ការបណ្តុះបណ្តាលអំពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន" ដល់មន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ដែលកំពុងបម្រើការងារនៅតំបន់ដាច់ស្រយាលតាមបណ្តោយព្រំដែន ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចំនួន ២ រូប ទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះនៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធដែលនឹងប្រព្រឹត្តធ្វើនៅខេត្តក្រចេះ ។

៥.២. ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីរបស់ក្រសួងសមាជិក ទៅចូលរួមប្រជុំក្រុមការងារអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនរបស់អាស៊ាន (ASOD Working Group on Law Enforcement) លើកទី១ នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ថ្ងៃទី១០-១១/០២/២០១៤ ។

៥.៣. ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមក្នុងសន្និសីទស្តីពី ការអនុវត្តច្បាប់គ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៨-២០/០២/២០១៤ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។

៥.៤. ត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី៨ ស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន នាថ្ងៃទី០៤-០៧/០២/២០១៤ នៅខេត្តកែប ។

៥.៥. ត្រៀមរៀបចំដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសវៀតណាម និង ប្រទេសឡាវ ។

៥.៦. បន្តទំនាក់ទំនងជាមួយស្ថានទូតចិន និងក្រសួងសន្តិសុខសាធារណៈចិន ពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

៥.៧. រៀបចំគណៈប្រតិភូថ្នាក់រដ្ឋមន្ត្រី ទៅចូលរួមជាមួយបណ្តាប្រទេសសមាជិក MOU ឆ្នាំ១៩៩៣ ក្នុងការរៀបចំព្រឹត្តិការណ៍ស្វែងរកការគាំទ្រក្នុងកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អង្គការសហប្រជាជាតិ នៅថ្ងៃទី១២-២១/៣/២០១៤ នៅទីក្រុងវីយែន ប្រទេសអូទ្រីស ។

៥.៨. ត្រៀមលក្ខណៈជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ អញ្ជើញទៅចូលរួមកិច្ចប្រជុំជាន់ខ្ពស់តាមផ្នែករបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អង្គការសហប្រជាជាតិ នៅថ្ងៃទី១៣/៣/២០១៤ នៅទីក្រុងវីយែន ប្រទេសអូទ្រីស ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- រៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនបន្ត ។
- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

**"ដើម្បីជូនជ្រាប"**

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

**"ដើម្បីមុខការ"**

-ឯកសារ